# មានរឿងចម្លែកកើតឡើងនៅទីក្រុងខ្ញុំ

## សៀវភៅអប់រំកុមារអំពីមេរោគកូរ៉ូណាដែលកើតឡើងនៅក្នុងពិភពលោកយើង



រៀបរៀងឡើងដោយ Dr. Shu-Chen Jenny Yen
បកប្រែដោយ Raline von Buelow រ៉ាលីន វ៉ន ប៊ូឡូ
រចនារូបភាពដោយ GLOPO. JCCREATION AND ART CENTER



# អារម្ភកថា



សៀវភៅនេះរៀបរៀងសម្រាប់មាតាបិតា អាណាព្យាបាល និង គ្រូបង្រៀនទាំងអស់ ដើម្បីអប់រំប្អូនៗកុមារដែលមានអាយុចាប់ពី ៣-៨ឆ្នាំអោយបានយល់ដឹងអំពីមេរោគកូរ៉ូណា ដែលកំពុងរាតត្បាតនៅក្នុងពិភពលោកយើងនេះ។

បញ្ហាដែលកើតឡើងចម្ពោះមុខអាចបណ្តាលអោយប្អូនៗកុមារមានការភ័យខ្លាច និង ងឿងឆ្ងល់ថាហេតុអ្វីក៏ពួកគេចាំបាច់ត្រូវនៅផ្ទះ? ហើយតើមានរឿងអ្វីកើតឡើងនៅក្នុងពិភពលោក?

ដំណោះស្រាយតែមួយដែលអាចអោយប្អូនៗបានយល់ដឹងគឺផ្សព្វផ្សាយតាមរយៈការអប់រំដែលសមស្របតាមវ័យ និង កំរិតយល់ដឹងរបស់ពួកគេ។

តួនាទីរបស់អ្នកដែលជាអាណាព្យាបាល គឺជួយពន្យល់ណែនាំពីសុវត្ថិភាពក្នុងគ្រួសារ និង សង្គមដល់ប្អូនៗកុមារថាមានមនុស្សជាច្រើនណាស់ដែលកំពុងធ្វើការស្រាវជ្រាវរកថ្នាំដើម្បីទប់ស្កាត់ជម្ងឺដ៏កាចសាហាវនេះ។





មានរឿងចម្លែកកើតឡើងនៅទីក្រុងខ្ញុំ។
ខ្ញុំមិនអាចទៅសាលារៀន ទៅលេងផ្ទះមិត្តភក្តិ រឺ ទៅលេងសួនកំសាន្តបាន។
ឪពុកម្តាយខ្ញុំមិនអាចចេញទៅធ្វើការ រីឯជីដូនខ្ញុំក៏ខ្លាចមិនហ៊ានចេញទៅផ្សារដែរ។
តាមផ្លូវមានភាពស្ងាត់ជ្រងំ តើមនុស្សទាំងអស់គ្នានៅឯណា?



អ្នកផ្សាយពត៌មានក្នុងទូរទស្សន៍ពាក់ម៉ាស
គ្រប់ៗគ្នា។

រីឯវេជ្ជបណ្ឌិត និង គិលានុប្បដ្ឋាយិកាស្លៀក
សំលៀកបំពាក់ចម្លែកការពារតាំងពីក្បាល
ដល់ចុងជើង។



តើទីក្រុងយើងមានជំងឺឬម៉ាក់?

ហេតុអ្វីគ្រប់គ្នាមានទឹកមុខស្រពោន ហើយខ្លះទៀតមាន
ទឹកមុខហាក់ដូចខឹងនឹងនរណាម្នាក់?



ចាំ កូនសម្លាញ់! ទីក្រុងយើងកើតជម្ងឺថ្មីមួយដែលហៅថា កូវីដ-១៩។
ជម្ងឺនេះឆ្លងទៅលើមនុស្សហើយឆ្លងរាលដាលយ៉ាងរហ័សបំផុតទូរទាំងពិភពលោក។
ជាអកុសល្យទីក្រុងយើងក៏កើតជម្ងឺនេះដែរ។



ម៉ាក់! ហេតុអ្វីប្រជាជនយើងមិនអាចទៅជួបវេជ្ជបណ្ឌិតដើម្បីពិនិត្យ
អោយថ្នាំតែម្តងទៅ?







ឥឡូវនេះប្រជាជនឈឺច្រើនណាស់កូន។

វេជ្ជបណ្ឌិត និង គិលានុប្បដ្ឋាយិកាទាំងអស់ខំប្រឹងធ្វើ ការទាំងយប់ថ្ងៃដើម្បីជួយអ្នកទាំងនោះប៉ុន្តែនៅតែមិនអាចឆ្លើយតបនឹងសំណូមពរអ្នក ដែលត្រូវការជំនួយនេះបានទៀត។

អ្នកវិទ្យាសាស្ត្រខិតខំស្រាវជ្រាវរិះរកវិធានការដើម្បីប្រឆាំងមេរោគនេះ តែអ្វីៗត្រូវទៀមទាររយៈ ពេលយូរ។



ម៉ាក់! តើកូនអាចនឹងឈើដៃរបស់ទេ?



ចាំកូន! ជាការងាយណាស់ដែលអ្នកទាំងអស់គ្នាអាចឈឺបានតែម៉ាក់ដឹងពីវិធីមួយ
ដែលជួយអោយកូនមានសុវត្ថិភាព។

អាំ! តើជាអ្វីទៅម៉ាក់? ប្រាប់កូនមកៗ



យើងនឹងធ្វើការសាកល្បងនូវបទពិសោធន៍មួយហៅថា “គម្លាតសង្គម”

តើមានន័យថាយ៉ាងមេចទៅម៉ាក់?

គឺមានន័យថាកូនត្រូវសំរាកនៅផ្ទះមិនទៅសាលារៀនពេលកូនមិនស្រួលខ្លួន។ បើយើងនៅផ្ទះយើងនឹងមិនឆ្លងមេរោគទេ។

ចាប់ពីពេលនេះទៅយើងត្រូវផ្អាកការជួបជុំផ្ទាល់ជាមួយមនុស្សទាំងឡាយ ដើម្បីទប់ស្កាត់ការចម្លងមេរោគនេះ។



ប្រសិនបើយើងត្រូវការចេញទៅក្រៅ យើងត្រូវរក្សាគម្លាតនៅឆ្ងាយពីគ្នា។

មិនត្រូវប៉ះពាល់វត្ថុផ្សេងៗ ហើយយកដៃមកប៉ះមុខមាត់ និង ភ្នែកយើងឡើយ។

យើងត្រូវលាងដៃជាមួយសាប៊ូ និង ទឹកក្តៅលើសពី២០វិនាទី
ដើម្បីលាងសំអាតមេរោគអោយចេញពីដៃរបស់យើង។



អ៎ា! កូនអាចធ្វើបាន។ តើប៉ុណ្ណឹងវាគ្រប់គ្រាន់ទេម៉ាក់?

កុំបារម្ភអីកូនសម្លាញ់!
មេរោគនេះមិនអាចឆ្លងបានឡើយបើគ្រប់គ្នាមានការប្រុងប្រយត្ន័ហើយរក្សាគម្លាត
អោយឆ្ងាយពីគ្នា។
មិនតែប៉ុណ្ណោះ ម៉ាក់ ប៉ា លោកតា និង លោកយាយ នឹងព្យាយាមរក្សាសុវត្ថិភាពរបស់កូន
មិនអោយមេរោគឆ្លងដល់កូនទេ។



កូនដឹងទេ អ្នកវិទ្យាសាស្ត្របានស្រាវជ្រាវឃើញថាប្រពន្ធ័ភាពស៊ាំនៃរាងកាយរបស់កុមារមានភាពរឹងមាំជាងមនុស្សចាស់ហើយអាចទប់ទល់នឹងជម្ងឺថ្មីនេះបាន។

អ៊ា! នេះមានន័យថាកូនអាចឈ្នះជម្ងឺនេះបាន មែនទេម៉ាក់?



ចំា! ប៉ុន្តែកូនត្រូវតែថែរក្សាគម្លាតអោយឆ្ងាយពីគ្នា។

អញ្ចឹង បានន័យថាកូនមិនអាចទៅលេងជាមួយមិត្តភក្តិកូនបានទេ មែនទេម៉ាក់?



ចា៎! កូនអាចជួបមិត្តភក្តិកូនបាន។
កូនអាចមើលកុន ឬ វីដេអូ និង ប្រាស្រ័យទាក់ទងជាមួយ
មិត្តភក្តិកូនតាមបណ្តាញអិនធឺណែត រឺ តាមរយៈទូរសព្ទ័។



ម៉ាក់! តើកូនត្រូវរង់ចាំយូរប៉ុណ្ណាទៅទើបអាចទៅលេងជាមួយមិត្តភក្តិបាន?
ហើយពេលណាទៅទើបជម្ងឺនេះនឹងសាបសូន្យ?
តើមានមនុស្សស្លាប់ច្រើនរឺទេ ម៉ាក់?



ម៉ាក់ក៏មិនដឹងដែរកូនសម្លាញ់!

កូនដឹងទេថាវេជ្ជបណ្ឌិត និង គិលានុប្បដ្ឋាយិកា
ខិតខំធ្វើការយ៉ាងមមាញឹកដើម្បីសង្គ្រោះជីវិតអ្នកជម្ងឺដោយគ្មានការរាថយឡើយ។
អ្នកទាំងអស់គ្នាធ្វើការយ៉ាងសកម្មនៅក្នុងមន្ទីរពេទ្យដោយគ្មានឱកាសទៅផ្ទះ
ជួបជុំក្រុមគ្រួសារ និង កូនរបស់គាត់ឡើយ។





តើកូនៗរបស់លោកវេជ្ជបណ្ឌិតមានអារម្មណ៍សោកសៅដូចម្ដេចទៅនៅពេលមិនបានជួប
ឪពុកម្ដាយរបស់គេ ម៉ាក់?





ចាំកូន! គេទាំងអស់គ្នាពិតជាសោកសៅណាស់ដោយ
មិនអាចឃើញមុខឪពុកម្ដាយគេរាល់ថ្ងៃដូចជាកូន។

ប៉ុន្តែគេពិតជាមានមោទនភាពដោយសារសេចក្ដីក្លាហានរបស់
ឪពុកម្ដាយគេក្នុងការប្រឆាំងជាមួយមេរោគដើម្បីសង្គ្រោះអាយុជីវិតប្រជាជនយើង។

អា៎! គេទាំងនោះអស្ចារ្យខ្លាំងណាស់! គេជា **វីរបុរស** របស់កូន!





គឺមានវីរបុរសច្រើនណាស់កូនដែលរួមគ្នាកំចាត់មេរោគនេះ។

អ្នកវិទ្យាសាស្រ្តធ្វើការស្រាវជ្រាវយ៉ាងស្វិតស្វាញដើម្បីស្វែងរកការទប់ទល់។

រីឯអ្នកដឹកជញ្ជូនទាំងប្រុសស្រីខំដើរចែកស្បៀងដល់ប្រជាជនដែលមិនអាចចេញក្រៅទៅរក

ចំណីអាហារបាន។



អ្នកកាសែតបានផ្សព្វផ្សាយពត៌មានសំខាន់ៗដល់យើងទាំងអស់គ្នា
តាមរយៈទូរទស្សន៍ សារពត៌មាន និង បណ្តាញអិនធឺណែត។
មានមនុស្សជាច្រើនដែលខិតខំធ្វើការយ៉ាងពេញទំហឹង
ព្រោះតែចង់អោយយើងគ្រប់គ្នារស់នៅដោយសុវត្ថិភាព។



អ៊ា! ពួកគាត់ពិតជា **អស្ចារ្យ** មែន!





មនុស្សជាច្រើនទូទាំងសកលលោកបានបរិច្ចាគលុយ
ទិញម៉ាស ស្រោមដៃ និង អ្វីៗច្រើនទៀតដើម្បីរក្សា
សុវត្ថិភាពរបស់លោកវេជ្ជបណ្ឌិត និង គិលានុប្បដ្ឋាយិកា
ពេលដែលលោកព្យាបាលអ្នកជម្ងឺ។

ប្រជាជនខ្លះទៀតបានផ្តល់ស្បៀងអាហារ និង
គ្រឿងបរិក្ខាផ្សេងៗដល់អ្នកជិតខាងដែលមិនអាចចេញ
ក្រៅបាន។

ម៉ាក់ និង ប៉ានឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីជួយពួកគេដែរ។

ម៉ាក់! តើកូនអាចធ្វើអ្វីបានខ្លះដើម្បីចូលរួមចំណែកនេះ?

ចុះកូនមានគំនិតយ៉ាងណាដែរ?



កូនអាចគូររូប និង សរសេរសំបុត្រថ្លែងអំណរគុណទៅមនុស្សដែលបាន
រួមចំណែកការពារប្រជាជនយើង។
កូនអាចចែកចាយល្បែងលេង និង សៀវភៅរឿងមួយចំនួនរបស់
កូនទៅដល់ក្មេងៗដែលមានតម្រូវការ។



គំនិតនេះពិតជាប្រសើរមែនកូនសម្លាញ់ម៉ាក់!
អញ្ចឹង! ឥឡូវនេះយើងចាប់ផ្តើមដំណើរការទៅកូន
ដើម្បីជួយដល់កុមារទាំងនោះ!



ហេតុការណ៍ដែលកើតឡើងនាពេលបច្ចុប្បន្ននេះប្រៀប
ដូចជាសមរភូមិមួយដែលមនុស្សក្នុងពិភពលោក
យើងរួមគ្នាប្រយុទ្ធប្រឆាំងទាំងអស់គ្នា។
ការថែរក្សាសុវត្ថិភាពខ្លួនឯង និង ការប្រុង
ប្រយត្ន័មិនចម្លងរោគទៅអ្នកដ៏ទៃគឺជាយុទ្ធសាស្រ្ត
ដ៏ល្អបំផុតសម្រាប់កំចាត់ជម្ងឺកូវីដ-១៩នេះ។



បាទ យល់ព្រម! កូននឹងលាងដៃតាមការណែនាំរបស់ម៉ាក់។
កូនមិនចេញក្រៅផ្ទះ ហើយធ្វើកិច្ចការសាលាតាមអិនធឺណែត។
បើយើងនៅក្នុងផ្ទះយើងមិនអាចឆ្លងជំងឺ ហើយក៏មិនចាំបាច់
ទៅមន្ទីពេទ្យដែរ។ ដូចនេះវេជ្ជបណ្ឌិត និង គិលានុប្បដ្ឋាយិកា
មានពេលវេលាគ្រប់គ្រាន់ដើម្បីថែរក្សាប្រជាជន
ដែលមានជម្ងឺ។



ពិតប្រាកដហើយ! យើងត្រូវរួមគ្នាកំចាត់មេរោគនេះដោយអនុវត្តន៍នូវ “គម្លាតសង្គម”

យល់ព្រមម៉ាក់! យើងនឹងជួបគ្នាពេលក្រោយតាមរយៈវីដេអូសន្ទនា!



# កំណត់សំគាល់សម្រាប់មាតាបិតា

ចាប់តាំងពីពេលដែលមានមេរោគកូរ៉ូណា ឬ កូវីដ-១៩ ក្នុងឆ្នាំ២០១៩នេះមក កុមារទូរទាំងពិភពលោកអាចនឹងមានបទពិសោធន៍ស្មុគ្រស្មាញ (ឧ:ការឃុំខ្លួននៅក្នុងផ្ទះ) ឬមានការភ័យខ្លាចនៅពេលបានឃើញរូបភាពមេរោគនេះតាមរយៈបណ្តាញផ្សព្វផ្សាយនានា។

វាជារឿងហេតុមួយដែលពិបាកនឹងពន្យល់ដល់ប្អូនៗកុមារថា ហេតុអ្វីមានគម្លាតសង្គមកើតឡើង? ហើយហេតុអ្វី គេមិនអាចលេងជាមួយមិត្តភក្តិបានដូចមុន?

សៀវភៅនេះស្វែងយល់អំពី៖

១. ការធានានូវសុវត្ថិភាពរបស់ប្អូនៗកុមារ

២. ការណែនាំកុមារក្នុងផ្លូវវិជ្ជមានលើការព្យាបាលយ៉ាងសកម្មរបស់វេជ្ជបណ្ឌិត និង ទង្វើរល្អរបស់មនុស្សដទៃទៀតក្នុងការទប់ស្កាត់មេរោគនេះ

៣. លើកទឹកចិត្ត និង បន្តការគាំទ្ររបស់ប្អូនៗកុមារក្នុងការរួមចំណែកយល់ដឹងពីភាពចាំបាច់នៃគម្លាតសង្គម។

# កំណត់សំគាល់សម្រាប់មាតាបិតា



កុមារទាំងឡាយតែងត្រូវការភាពស្រលាញ់ និង ការយកចិត្តទុកដាក់ពីសុវត្ថិភាពរបស់ពួកគេ ពីឪពុកម្តាយនៅពេលដែលមានរឿងភ័យខ្លាចកើតឡើង។

តួនាទីរបស់អ្នកជាឪពុកម្តាយត្រូវបង្ហាញនូវការយកចិត្តទុកដាក់ដល់បុត្រធិតាក្នុង តំណាក់កាលដ៏តានតឹងនេះ។ ធ្វើយ៉ាងណាអ្នកត្រូវជួយអប់រំពួកគេអោយអនុវត្តន៍នូវ គម្លាតសង្គម ដោយធ្វើការទំនាក់ទំនងជាមួយមិត្តភក្តិតាមបណ្តាញអិនធើណែត នាពេលបច្ចុប្បន្ននេះ។

មិនតែប៉ុណ្ណោះអ្នកត្រូវលើកទឹកចិត្តបុត្រធិតាអោយមានទំនុកចិត្តលើវីរបុរសទាំងឡាយ ដែលខិតខំធ្វើកិច្ចការយ៉ាងសស្រាក់សស្រាំដើម្បីរួមគ្នាកំចាត់មេរោគដែលកំពុងកើតឡើងនៅក្នុង ពិភពលោកយើងនេះ។

សរុបសេចក្តីទៅ ការបង្ហាញនូវសមត្ថភាពយល់ដឹងក្នុងការថែរក្សាសុវត្ថិភាពរបស់អ្នក និង គ្រួសារ នឹងមិនចម្លងមេរោគទៅមនុស្សដ៏ទៃ ទាំងនោះហើយគឺជាសកម្មភាពរបស់វីរបុរស!

# Note About the Author

Dr. Shu-Chen “Jenny” Yen is an associate professor in the Department of Child and Adolescent Studies, California State University, Fullerton. She created and shared her first social story with the public for the 911 terrorist attacks by the al-Qaeda on the United States on September 11, 2001. To date, she has created several social stories for young victims who were impacted by typhoons, earthquakes, hurricanes in Taiwan, China, the Philippines, Puerto Rico, and the USA. With trauma-informed care practice in mind, she hopes this social story can help children living in the impacted areas find love and courage. She was the 2018 P.E.A.C.E Award recipient from the Peace Educators Allied for Children Everywhere (P.E.A.C.E.) She is nominated by the Educators for Peaceful Classrooms and Communities (EPCC) for the 2020 Honor an Early Childhood Educator Award, California Association for the Education of Young Children (CAAEYC).

# Acknowledgement

I would like to thank the following people for providing feedback on the story: Dr. Kathy Thornburg, Dr. Sandy Baba, Dr. Feiyan Chen, Dr. Cary Larson-McKay, Dr. Janna Kim, Dr. Shu-Nu Yen, Shu-Ling Yen, Joyce Daniel, Tom Pfaff, and Tina Pfaff. I also would like to thank the kids who helped test the story: Austen Liu, Allison Yu, Caitlyn Yu, Kaja Andersen, Dana Yen, Calvin Pfaff, Simon Pfaff, and Luke Pfaff. A huge thank you to my daughter, Angela Lee, for her careful edit of the story; my son, Eric Lee, for his detailed proof-reading; and my husband, Michael Lee, for starving so I could finish this story. Lastly, I would like to thank Shu-ChiungChang and GLOPO.JCCREATION AND ART CENTER for their timely assistance in helping with the illustrations and animation.

NAEYC Asian Interest Forum would like to give our heartfelt thanks to Raline von Buelow, Phalpisey Aum (typing), and Bopha Ouk (editing) for their support in adapting and translating this book into Cambodian.

Copyright ©2020 by Shu-Chen Yen. All rights reserved. This book or any portion may not be reproduced, relabeled, or used in any commercial manner whatsoever without the express written permission of the author. Permission is not required for personal or professional use (e.g., classroom setting). For more information, please contact Shu-Chen Yen at syen@fullerton.edu.

All the illustrations are pro bouno work for the book, not for commercial purpose. Copyright  2020 by GLOPO.JCCREATION AND ART CENTER. All rights reserved. Any forms of reproduction or relabelling without permission is an illegal act. For more information, please contact GLOPO.JCCREATION AND ART CENTER at work@jccaac.com.